# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៣ ខែតុលា២០១២ឆ្នាំ

# ជប៉ុនផ្តល់ ៩២,៥៥០ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពតាបាំងក្នុងខេត្តកំពង់ឆ្នាំង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ)រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៩២,៥៥០ដុល្លាអាមេរិកដល់មន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ឆ្នាំងសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពតាបាំងក្នុងខេត្តកំពង់ឆ្នាំង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយឯកឧត្តម គូរ៉ូគីម៉ាសាហ៊្វូមី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក ដោក ប៊ុនថុន ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ឆ្នាំងនៅស្ថានទូតជប៉ុន។



ជាមួយនឹងជំនួយនេះ ប្រព័ន្ធស្រោចស្រពតាបាំងនឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ឆ្នាំង។ គម្រោងនេះរួមបញ្ចូលការជួសជុលទំនប់អាងទឹកប្រវែង៧០០ម៉ែត្រ ការជួសជុលប្រឡាយរងប្រវែង៣០០ម៉ែត្រ និងការសាងសង់សំណង់ទ្វារទឹកចំនួន២កន្លែង។ យើងរំពឹងថា វានឹងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ១,៣៥២គ្រួសារនៅក្នុងតំបន់។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ឆ្នាំង ប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អប្រសើរជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ)*ជំនួយគូសាណូណិ*(របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និងភាព

អកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ ១៩៩១ រដ្ឋាភិបាល ជប៉ុនបានផ្តល់ថវិកាជាង ៤៨លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៧៧គម្រោងនៅទូទាំងប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣៣៣០-២១៤-០២៣ទូរសារ៖ ១៦១-២១៧-*
*អ៊ីមែល:* eco.jpn@.pp.mofa.go.jp
*គេហទំព័រ:* *http://www.kh.emb-japan.go.jp*